# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# របាយការណ៍វឌ្ឍនភាព គិតត្រឹមខែមីនា ឆ្នាំ២០០៩

## ១-សេចក្តីផ្តើម

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាកម្មវិធីកំណែទម្រង់ជាអាទិភាពនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលបានចាប់ផ្តើមនៅក្នុងខែធ្នូ ឆ្នាំ២០០៤ក្នុងគោលដៅប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជាឱ្យទៅជាប្រព័ន្ធមួយ ដែលមានលក្ខណៈស្របទៅតាមនិយាមអន្តរជាតិ ដែលមានការទទួលស្គាល់ជាទូទៅនៅត្រឹមឆ្នាំ ២០១៥។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំជាបួនជំហានដែលត្រូវដាក់អនុវត្តជាដំណាក់កាល។ ដើម្បីសម្រេចនូវគោលដៅចំបងនៃជំហាននីមួយៗ (១)ការបង្កើនភាពជឿទុកចិត្តបាននៃថវិកា (២) ករបង្កើនគណនេយ្យភាពហិរញ្ញវត្ថុដើម្បីធ្វើឱ្យប្រសើរឡើងការត្រួតពិនិត្យផ្ទៃក្នុង និងមានគណនេយ្យភាពរបស់អ្នកគ្រប់គ្រងថវិកា (៣)ការផ្សារភ្ជាប់គ្នារវាងថវិកា និង គោលនយោបាយ និង(៤)បង្កើនគណនេយ្យភាពសមិទ្ធកម្មរបស់អ្នកគ្រប់គ្រង។

នៅក្នុងដំណាក់កាលនីមួយៗ ផែនការសកម្មភាពច្បាស់លាស់ត្រូវរៀបចំ និងកំណត់ដើម្បីសម្រេចគោលដៅជាយុទ្ធសាស្ត្រតាមជំហាននីមួយៗ ព្រមទាំង និងការដាក់ចេញសកម្មភាពគាំទ្រដទៃទៀត ដោយផ្សារភ្ជាប់ជាមួយយន្តការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ផ្អែកលើកន្សោមសូចនាករណ៍សមិទ្ធកម្មដែលបានដកស្រង់ចេញពីក្របខ័ណ្ឌការងារគណនេយ្យភាពហិរញ្ញវត្ថុ និងចំណាយសាធារណៈ។

កិច្ចប្រជុំត្រួតពិនិត្យឡើងវិញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់ទី១ ត្រូវបានប្រព្រឹត្តទៅនៅថ្ងៃទី ២៨-២៩ ខែឧសភា ឆ្នាំ២០០៨ ដោយបានវាយតម្លៃខ្ពស់លើការសម្រេចការកសាងបាននូវភាពជឿទុកចិត្តបាននៃថវិកា ហើយដែលអនុញ្ញាតឱ្យចាប់ផ្តើមបោះជំហានឆ្ពោះទៅកាន់ដំណាក់កាលទី ២ ដើម្បីសម្រេចគោលបំណងនៃការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការកាលពី

ថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ២០០៨។ ឆ្នាំ ២០០៨ កន្លងមកត្រូវបានចាត់ទុកជារយៈពេលដំបូងនៃដំណាក់កាលទី ២ ហើយក៏ជាពេលវេលានៃផ្លាស់ប្តូរពីដំណាក់កាលទី ១ និងការកសាងមូលដ្ឋានសម្រាប់ការបោះជំហានទៅមុខនៃដំណាក់កាលទី២នេះដែរ។

របាយការណ៍វឌ្ឍនភាពនេះ នឹងធ្វើការបង្ហាញអំពីសកម្មភាពការងារកំណែទម្រង់ដែលបានអនុវត្តក្នុងដំណាក់កាលទី១កន្លងមក មកទល់នឹងខែមីនា ឆ្នាំ២០០៩ ដោយធ្វើការបង្ហាញឱ្យឃើញអំពីស្ថានភាពនៃការអនុវត្តសកម្មភាពកំណែទម្រង់ដំណាក់កាលទី១/ជំហានទី ១ ជាពិសេសការវាស់វែងសមិទ្ធផលមួយចំនួនដោយផ្អែកលើកន្សោមសូចនាករណ៍ដែលត្រូវបានរៀបចំឡើងដើម្បីពិនិត្យមើលភាពគង់វង្សនៃភាពជឿទុកចិត្តបាននៃថវិកាដែលជាសមិទ្ធផលនៃដំណាក់កាលទី១, ការផ្លាស់ប្តូរពីដំណាក់កាលទី១ ទៅកាន់ដំណាក់កលទី២ ដែលជាពេលវេលានៃការកសាងមូលដ្ឋានសម្រាប់ការចេញដំណើរនៃដំណាក់កាលទី ២, វឌ្ឍនភាពនៃការអនុវត្តសកម្មភាពការងារដំណាក់កាលទី ២ ដែលបានកំណត់នៅក្នុងផែនការសកម្មភាពរួម ព្រមទាំងបញ្ហាប្រឈមមួយចំនួនដែលបានជួបប្រទះ។

## ២. វឌ្ឍនភាពក្នុងវិស័យគោលគន្លឹះនៃដំណាក់កាលទី ១/ជំហានទី ១

គួររំលឹកឡើងវិញថា គោលដៅចំបងនៃជំហានទី ១ របស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាការធ្វើឱ្យប្រសើរឡើងនូវភាពជឿទុកចិត្តបាននៃថវិកាដែលក្នុងនោះ សំដៅដល់:

- ធ្វើឱ្យប្រសើរឡើងការប្រមូល និងគ្រប់គ្រងចំណូល តាមរយៈការរៀបចំគោលនយោបាយការព្យាករណ៍ចំណូល និងការគ្រប់គ្រងចំណូលឱ្យបានប្រសើរឡើង
- កែលម្អការរៀបចំថវិកា តាមរយៈការកំណត់ច្បាស់លាស់នូវគោលបំណងសម្រាប់ការប្រើប្រាស់ ភាពប្រាកដនិយម និងភាពគ្រប់ជ្រុងជ្រោយនៃថវិកា
- កែលម្អដំណើរការនៃការអនុវត្តថវិកា ផ្អែកលើដំណើរការអនុវត្តថវិកាមួយដែលមានលក្ខណៈគាំពា និងអាចប្រមើលទុកជាមុនបាន។

វឌ្ឍនភាពក្នុងវិស័យគន្លឹះនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី១/ជំហានទី១ ផ្តោតទៅសមិទ្ធកម្មក្នុងផ្នែកចំណូល, ការកែលម្អការរៀបចំថវិកា និង ការកែលម្អការអនុវត្តថវិកា។

- **សមិទ្ធកម្មក្នុងផ្នែកចំណូល**

ជាមធ្យម ចំណូលពន្ធក្នុងស្រុកសរុបនៃអំឡុងពេលឆ្នាំ ២០០៥-២០០៧ សម្រេចបាន ១៧.៥% ខ្ពស់ជាងគោលដៅកំណត់នៅក្នុងច្បាប់ និងក្នុងឆ្នាំ ២០០៨ សម្រេចបានប្រមាណ ២៤% ខ្ពស់ជាងគោលដៅច្បាប់ (ជាមធ្យម វឌ្ឍនភាពនេះសម្រេចបានទាបជាង ៨% បើប្រៀបជាមួយលទ្ធផលធៀបនឹងច្បាប់នៅក្នុងរយៈកាលឆ្នាំ២០០១-២០០៣)។ វឌ្ឍនភាពនៃត្រីមាសទី១ ឆ្នាំ២០០៩ ត្រូវបានប៉ាន់ប្រមាណថាសម្រេចបានប្រហែល២៣% នៃច្បាប់ថវិកាបើប្រៀបជាមួយនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០០៨ គឺសម្រេចបាន៣០% ។

ចំពោះចំណូលដែលបានពីប្រភពពន្ធផ្ទាល់ ជាមធ្យមមានកំណើន៣៩%ក្នុងរយៈពេលនៃឆ្នាំ ២០០៥-២០០៧ និងសម្រេចបានប្រមាណ ៤៥%ក្នុងឆ្នាំ ២០០៨ (បើប្រៀបជាមួយរយៈពេលឆ្នាំ ២០០១-២០០៣ ជាមធ្យមសម្រេចប្រមាណ០៣%)។ វឌ្ឍនភាពនៃត្រីមាសទី១ ឆ្នាំ២០០៩ ត្រូវបានប៉ាន់ប្រមាណថាសម្រេចបានប្រហែល២៦% នៃច្បាប់ថវិកាបើប្រៀបជាមួយនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០០៨ គឺសម្រេចបាន៣៣% ។

ចំពោះចំណូលដែលបានពីប្រភពពន្ធមិនផ្ទាល់ជាមធ្យមមានកំណើន២៨%ក្នុងរយៈពេលឆ្នាំ ២០០៥-២០០៧ និងសម្រេចបានប្រមាណ ២៤%ក្នុងឆ្នាំ ២០០៨ (បើប្រៀបជាមួយរយៈពេលឆ្នាំ ២០០១-២០០៣ ជាមធ្យមសម្រេចប្រមាណ០៩%)។ វឌ្ឍនភាពនៃត្រីមាសទី១ ឆ្នាំ២០០៩ ត្រូវបានប៉ាន់ប្រមាណថាសម្រេចបានប្រហែល២១% នៃច្បាប់ថវិកាបើប្រៀបជាមួយនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០០៨ គឺសម្រេចបាន២៩% ។

- **ការកែលម្អការរៀបចំថវិកា**

ការកែលម្អការរៀបចំថវិកាសម្រេចបានតាមរយៈការអនុម័តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុកាលពីខែឧសភា ឆ្នាំ ២០០៨ ដែលច្បាប់នេះ ផ្តល់នូវក្របខ័ណ្ឌគតិយុត្តសម្រាប់ការអនុវត្តជាជំហានៗដើម្បីកែលំអប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាឆ្ពោះទៅរកបទដ្ឋានអន្តរជាតិ និងដើម្បីគាំទ្រការអនុវត្តច្បាប់រៀបចំអង្គការថ្មីសម្រាប់គ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោម

ជាតិ។ ប្លង់គណនេយ្យថ្មី និងចំណាត់ថ្នាក់សេដ្ឋកិច្ចថ្មីត្រូវបានដាក់ឱ្យអនុវត្ត ហើយបានកែលម្អជាបន្តបន្ទាប់ក្នុងឆ្នាំ២០០៨។ ផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានប្រើប្រាស់ជាឧបករណ៍ដើម្បីធ្វើសមាហរណកម្មថវិកាចរន្ត ថវិកាមូលធន និងថវិការបស់ដៃគូអភិវឌ្ឍន៍ របស់គ្រប់ក្រសួង-ស្ថាប័ន ទន្ទឹមនឹងនេះការរៀបចំថវិកាតាមកម្មវិធីក៏ត្រូវបានដាក់ឱ្យសាកល្បងជាបណ្តើរៗនៅក្រសួងចំនួន ០៨ ដោយផ្សារភ្ជាប់ជាមួយការរៀបចំយន្តការគាំទ្រមួយចំនួនទៀតដូចជាការវគ្គបណ្តុះបណ្តាលជាដើម។ ប្រព័ន្ធ **Software** សម្រាប់ការគ្រប់គ្រងបំណុលត្រូវបានដាក់ឱ្យដំណើរការ និងឯកសារប្រចាំខែ DMFAS ស្តីអំពីបំណុល បំណុលដែលអោយគេខ្ចី ( on-lending loans ) និងជំនួយ ( grants ) ត្រូវបានរៀបចំបង្កើតឡើងព្រមជាមួយការកែលម្អសមត្ថភាពក្នុងការគ្រប់គ្រងបំណុល។ វិមជ្ឈការសារពើពន្ធត្រូវបានធ្វើការពិនិត្យ និងសិក្សាក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ និងច្បាប់ស្តីប្រព័ន្ធហិរញ្ញវត្ថុ។

- **ការកែលម្អការអនុវត្តថវិកា**

ប្លង់គណនេយ្យថ្មីត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។ បំណុលកកស្ទះត្រូវបានលុបបំបាត់ទាំងស្រុង ហើយប្រព័ន្ធ **software Conical Hat** ត្រូវបានដាក់ឱ្យដំណើរការដើម្បីតាមដាន អាយុកាលបំណុល។ លទ្ធកម្មសាធារណៈត្រូវបានធ្វើវិសហមជ្ឈការទៅឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីរៀបចំលទ្ធកម្មដោយខ្លួនឯងក្នុងកម្រិតថវិកាមួយកំណត់ ព្រមជាមួយការកែលម្អនីតិវិធី និងវិធីសាស្ត្រលទ្ធកម្ម។ ដំណាក់កាលដំបូងនៃអភិក្រមអនុវត្តថវិកាជាលំហូរត្រូវបានដាក់ឱ្យដំណើរការសម្រាប់ឆ្នាំ២០០៧ ហើយអភិក្រមការងាររួមក៏ត្រូវបានសិក្សាដើម្បីរៀបចំបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុក៏ត្រូវបានកែលម្អដោយការធ្វើវិសហមជ្ឈការទៅតាមបណ្តាក្រសួង ស្ថាប័នចំណាយតាមរយៈការពង្រាយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុជាបណ្តើរៗទៅប្រចាំនៅក្រសួង ស្ថាប័ន។ផែនការចំណាយនិងចំណូលប្រចាំត្រីមាសត្រូវបានដាក់ឱ្យអនុវត្ត បន្ថែមលើនេះការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ការប្រមូលចំណូលនិងចំណាយត្រូវបានពង្រីកកាន់តែប្រសើរឡើង។

ក្នុងកំឡុងឆ្នាំ ២០០៥-២០០៧ ចំណាយសរុបតាមត្រីមាសជាមធ្យមសម្រេចបាន ១២.៨%, ៣៥.៨%, ៦១.៩% និង ៩៧.៣% ទៅតាមលំដាប់ត្រីមាសទាំងបួនក្នុងឆ្នាំ។ ក្នុងឆ្នាំ២០០៨ ចំណាយតាមលំដាប់ត្រីមាសទាំងបួនសម្រេចបាន ១៤.៧%, ៤៣.៧%, ៧១.៦% និង១០៧.៥% និងនៅក្នុងត្រីមាសទី១ នៃឆ្នាំ២០០៩ នេះ ត្រូវបានប៉ាន់ប្រមាណសម្រេចបាន ១៩%។

ដោយឡែកចំណាយតាមប្រភេទទាំងបី: បៀវត្ស ទំនិញ/សេវា និងមូលធន ក្នុងអំឡុងឆ្នាំ ២០០៥-២០០៧ សម្រេច ៩២%, ១០៤% និង ៨៦%ក្នុងលំដាប់ប្រភេទនីមួយៗ។ ក្នុងឆ្នាំ ២០០៨ សម្រេចបាន ១១៥.៨%, ១០៧% និង១០៨% ក្នុងលំដាប់ប្រភេទនីមួយៗ។ សម្រាប់ត្រីមាសទី ១នៃឆ្នាំ ២០០៩ ត្រូវបានប៉ាន់ប្រមាណសម្រេចបាន ២០%, ១៩.៦% និង ២៥.៦% ធៀបនឹង ២០%, ១៦% និង ១៤% ក្នុងរយៈពេលដូចគ្នានៃឆ្នាំ២០០៨។

## ៣. ការផ្លាស់ប្តូរពីដំណាក់កាលទី ១ ទៅដំណាក់កាលទី២: កសាងមូលដ្ឋានដំណើរការសម្រាប់ដំណាក់កាលទី ២

យន្តការគ្រប់គ្រង និងសម្របសម្រួលកម្មវិធីទាំងមូល និងតាមក្រសួង ស្ថាប័ន(ចំនួន ៣៨) ត្រូវបានបង្កើតឡើង និងមានដំណើរការជាប្រចាំ ដោយមានមូលដ្ឋានគតិយុត្ត សេចក្តីណែនាំ និង បទបញ្ជាផ្ទៃក្នុងកំណត់អំពីដំណើរការងារ និងរបបរបាយការណ៍ជាទៀងទាត់យ៉ាងច្បាស់លាស់។ បន្ទាប់ពីកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពកម្មវិធីកែទម្រង់ដំណាក់កាលទី១ កាលពីថ្ងៃទី ២៨-២៩ ខែឧសភា ឆ្នាំ២០០៨ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានជួបប្រជុំចំនួន ០៤លើក ក្នុងគោលបំណង:

-រៀបចំយន្តការសម្របសម្រួល និងបទបញ្ជាផ្ទៃក្នុង កម្មវិធីប្រជុំ និងសិក្ខាសាលាបច្ចេកទេសសម្រាប់ជួយផ្តល់ការណែនាំ និងបទពិសោធន៍ដើម្បីរៀបចំផែនការសកម្មភាពក្រសួង ស្ថាប័ន ព្រមទាំងកម្មវិធីបណ្តុះបណ្តាល និងការផ្តល់ប្រាក់លាភការផ្អែកលើលទ្ធផលការងារ (ប្រជុំថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៨)។

-ពិនិត្យមើលសេចក្តីព្រាងផែនការសកម្មភាពក្រសួង ស្ថាប័ននិងការពិនិត្យបញ្ចប់បទបញ្ជាផ្ទៃក្នុងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ប្រជុំថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០០៨)។

-អនុម័តបទបញ្ជាផ្ទៃក្នុងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការបង្ហាញសេចក្តីណែនាំសម្រាប់ការផ្តល់ប្រាក់លាភការដោយផ្អែកលើលទ្ធផលការងារ (ប្រជុំថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០០៨ )។

-ពិនិត្យបញ្ចប់ផែនការសកម្មភាពរបស់ក្រសួង ស្ថាប័ន និងពិនិត្យទម្រង់របាយការណ៍វឌ្ឍនភាពរបស់ក្រសួង ស្ថាប័ន (ប្រជុំថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០០៩)។

លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានសម្របសម្រួលរៀបចំសិក្ខាសាលាបច្ចេកទេសស្តីពីវិស័យជំនាញរបស់អគ្គនាយកដ្ឋាន/នាយកដ្ឋានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការផ្តល់បទពិសោធន៍ក្នុងការរៀបចំផែនការសកម្មភាពចំនួន ១២លើក ដល់មន្ត្រីនៃក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ស្ថាប័ន និង បានបញ្ជូនមន្ត្រីលេខាធិការដ្ឋានទៅធ្វើបទបង្ហាញ និងការពន្យល់ជាលម្អិតអំពីការរៀបចំផែនការសកម្មភាពនៅតាមបណ្តាក្រសួង ស្ថាប័នថែមទៀត។ ជាលទ្ធផល ផែនការសកម្មភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ (៣៧)ត្រូវបានរៀបចំរួចរាល់ និងអាចចាប់ដំណើរការអនុវត្តបាន។ នៅក្នុងក្របខ័ណ្ឌនៃជម្រុញការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងជម្រុញការចូលរួមអនុវត្តផែនការសកម្មភាព គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានស្នើឱ្យក្រសួង ស្ថាប័ននីមួយៗ រៀបចំពិធីប្រកាសការអនុវត្តជាផ្លូវការផែនការសកម្មភាពរបស់ខ្លួននៅក្នុងក្រសួង ស្ថាប័ន ដែលមកទល់បច្ចុប្បន្នក្រសួង ស្ថាប័នមួយចំនួនបានរៀបចំរួចហើយ មួយចំនួនទៀតកំពុងត្រៀមរៀបចំ។

## ៤. ការវាស់វែងសមិទ្ធកម្មសម្រាប់ការអនុវត្តសកម្មភាពកំណែទម្រង់ដំណាក់កាលទី២

ការត្រួតពិនិត្យមើលការអនុវត្តសកម្មភាពកំណែទម្រង់ដំណាក់កាលទី២ បានផ្តោតលើវឌ្ឍនភាពនៃផែនការសកម្មភាពទាំងបីប្រភេទដែលបានកំណត់នៅក្នុងផែនការសកម្មភាពរួមនោះគឺការពិនិត្យមើលវឌ្ឍនភាពសកម្មភាពជំហានទី១ដែលត្រូវបន្តពង្រឹងក្នុងដំណាក់កាលទី២, វឌ្ឍនភាពសកម្មភាពដើម្បីសម្រេចគោលបំណងផ្ទាល់នៃជំហានទី ២ និងវឌ្ឍនភាពសកម្មភាពសម្រាប់ជំហានបន្ទាប់។

### ៤.១ សកម្មភាពជំហានទី១ ដែលត្រូវបន្តពង្រឹងនៅក្នុងដំណាក់កាលទី២

ការពិនិត្យមើលវឌ្ឍនភាពនៃសកម្មភាពទាំងនេះដែលរៀបចំក្រោមគោលបំណងចំនួនបួន គឺដើម្បីធានាថាភាពជឿទុកចិត្តបាននៃថវិកាដែលជាសមិទ្ធផលនៃការអនុវត្តកម្មវិធីកំណែទម្រង់ដំណាក់កាលទី១ នៅតែរក្សាបាន ដើម្បីគាំទ្រដល់ការសម្រេចគោលបំណងនៃកំណែទម្រង់ជំហានទី ២ "**ការធ្វើឱ្យប្រសើរឡើង គណនេយ្យភាពហិរញ្ញវត្ថុ**" ។

- **បន្តកែលម្អរដ្ឋបាល និង គោលនយោបាយចំណូល**

គោលនយោបាយចំណូលរយៈពេលមធ្យម រួមទាំងប្រេង និងឧស្ម័ន ត្រូវបានកែលម្អ និងធ្វើបច្ចុប្បន្នភាព ទន្ទឹមនេះ សេចក្តីព្រាងដើម្បីធានាតម្លាភាព និងផ្តល់ព័ត៌មានក្នុងការគ្រប់គ្រងចំណូលដែលបានពីវិស័យឧស្សាហកម្មទាញផលពីប្រេង ឧស្ម័ន និងប្រភពធនធានរ៉ែដទៃទៀត ត្រូវបានរៀបចំ និងត្រៀមដាក់ឱ្យមានការពិភាក្សានៅក្នុងដើមខែមេសា។ សេចក្តីព្រាងច្បាប់កាស៊ីណូត្រូវបានពិនិត្យឡើងវិញដើម្បីជម្រុញការអនុម័តឱ្យបានឆាប់រហ័ស ហើយច្បាប់ស្តីពីការធានារ៉ាប់រងក៏ត្រូវបានធ្វើវិសោធនកម្ម។ អនុក្រឹត្យស្តីពីការធានារ៉ាប់រងខ្នាតតូច អនុក្រឹត្យស្តីពីមីក្រូហិរញ្ញវត្ថុ និងអនុក្រឹត្យស្តីពីការចេញផ្សាយនិងធ្វើពាណិជ្ជកម្មមូលប័ត្រមិនមែនរដ្ឋាភិបាល ប្រកាសអន្តរក្រសួងស្តីពីកម្រៃនៃការចេញលេខប្រវេទន៍ផលិតផលគ្រឿងសំអាង សេចក្តីព្រាងតារាងកំរៃជើងសារ និង សេចក្តីព្រាងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់ក្រុមហ៊ុនប្រកបសេវាកម្មវាយតំលៃ និង សេវាកម្មអចលនវត្ថុ សេចក្តីព្រាងស្តង់ដារវាយតំលៃអចលនវត្ថុ សេចក្តីព្រាងបទប្បញ្ញត្តិមូលប័ត្រ ត្រូវបានព្រាងរួចរាល់ហើយ។ ក្របខ័ណ្ឌគោលនយោបាយ និង យុទ្ធសាស្ត្រមីក្រូហិរញ្ញវត្ថុ ត្រូវបានរៀបចំ និងកំពុងដំណើរការបោះពុម្ពផ្សព្វផ្សាយ។ គម្រោង ASYCUDA ជំហានទី៣ ត្រូវបានពង្រីកនៅតាមមាត់ច្រកសំខាន់ៗចំនួន០៤កន្លែង។ ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍អចលនវត្ថុ ត្រូវបានបង្កើត។ ក្រសួងបានចេញប្រកាសស្តីពីការគ្រប់គ្រងការត្រួតពិនិត្យ និងការផ្តល់អាជ្ញាប័ណ្ណជូនបុគ្គលអភិវឌ្ឍន៍អចលនវត្ថុ ប្រកាសស្តីពីការធានារ៉ាប់រងអាយុជីវិត ប្រកាសស្តីពីគោលការណ៍ណែនាំផ្នែកគណនេយ្យ សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់។ ក្របខ័ណ្ឌច្បាប់នានាដែលពាក់ព័ន្ធ នឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ នៅតាមបណ្តាក្រសួង ស្ថាប័ន ត្រូវបានសិក្សា និងពិនិត្យឡើងវិញ ដើម្បីពង្រឹងការគ្រប់គ្រងចំណូល

មិនមែនសារពើពន្ធ រួមទាំងការពិនិត្យលើការគ្រប់គ្រងចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ។ គណៈកម្មាធិការអន្តរក្រសួងដើម្បីរៀបចំយន្តការគ្រប់គ្រងចំណូលសេវាចុះបញ្ជីយានយន្ត និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទត្រូវបានបង្កើត។

- **បន្ទាត់គោលម្ភការគ្រប់គ្រងបំណុល**

បន្ទាប់ពីប្រព័ន្ធ **Software** ត្រូវបានរៀបចំហើយនោះ ទិន្នន័យហិរញ្ញប្បទានសម្បទាន កម្ចីបន្ត និងហិរញ្ញប្បទានឥតសំណង ព្រមទាំងទិន្នន័យការទូរទាត់សេវាបំណុលបានត្រូវ ដាក់បញ្ចូលទៅក្នុងប្រព័ន្ធ **Software** ថ្មី ហើយរបាយការណ៍គំរូអំពីហិរញ្ញប្បទានសម្បទានក្រៅ ប្រទេសនិងកម្ចីបន្ត និងសេចក្តីព្រាងគោលការណ៍ណែនាំក្នុងការគ្រប់គ្រងបំណុលត្រូវរៀប ចំឡើង។ វគ្គបណ្តុះបណ្តាលអំពីមូលដ្ឋានគ្រឹះនៃការប្រើប្រាស់ប្រព័ន្ធ **DMFAS** ត្រូវបានរៀបចំ សម្រាប់មន្ត្រីនាយកដ្ឋាន និងមន្ត្រីអគ្គនាយកដ្ឋានរតនាគារជាតិ ហើយមន្ត្រីទទួលបន្ទុកការងារគ្រប់គ្រងបំណុល បានចូលរួមវគ្គសិក្សាអំពីការគ្រប់គ្រងបំណុលតាម **DMFAS** ដែលរៀបចំដោយ **UNCTAD** និងធ្វើទស្សនកិច្ចសិក្សាទៅប្រទេសហ្វីលីពីនស្វែងយល់អំពីអំពីការគ្រប់គ្រងបំណុលតាម **DMFAS** ថែមទៀត។

- **បន្ទាត់គោលម្ភការគ្រប់គ្រងសាច់ប្រាក់ និង ការគ្រប់គ្រងគណនីធនាគារ**

នៅដើមឆ្នាំ ២០០៨ គណនីចរន្តរបស់ក្រសួង ស្ថាប័ន នៅធនាគារពាណិជ្ជ និងធនាគារជាតិ មានចំនួន ១៨៧ ជាបន្តបន្ទាប់អគ្គនាយកដ្ឋានរតនាគារជាតិបានចាត់វិធានការណ៍បិទគណនីចរន្តចំនួន ១៣ និងបានបង្កកគណនីចរន្តចំនួន ៤២ ។ ក្នុងឆ្នាំ ២០០៩ គណនីចរន្តដែលរកឃើញមានចំនួន ១៧៤ គិតមកដល់ត្រឹមថ្ងៃ ៣១ ខែមីនា ឆ្នាំ ២០០៩ គណនីចំនួន៦០ ត្រូវបានបិទ និង ៣៣គណនី ត្រូវបានបង្កក ហើយនិងកំពុងពិនិត្យឡើងវិញនូវគណនីពាក់ព័ន្ធមួយចំនួនដើម្បីឱ្យប្រាកដថាជាគណនីក្រៅគម្រោង។

ចំពោះការប្រើប្រាស់ប្រព័ន្ធធនាគរ គិតមកដល់ខែមីនា ឆ្នាំ២០០៩ ក្រសួង ស្ថាប័ន ចំនួន ២៧ (លើចំនួនសរុប ៣៨) និងអង្គភាព មន្ទីរចំនួន ៣២ (លើចំនួនសរុប ៥៨) បានបើកគណនីសម្រាប់ការផ្តល់បៀវត្សដល់មន្ត្រីរាជការនៅធនាគារ ANZ ដែលក្នុងនោះគណនីរបស់ក្រសួង ស្ថាប័នចំនួន ១៧ កំពុងដំណើរការពិតប្រាកដ។ ការជម្រុញសកម្មភាព

ប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ការបើកបៀវត្សកំពុងអនុវត្តជាបន្ត។ ទន្ទឹមនឹងនេះ ប្រព័ន្ធធនាគារជាតិ ក៏ត្រូវបានពង្រីកប្រើប្រាស់នៅក្នុងរាជធានី-ខេត្តចំនួន ២០លើចំនួនសរុប ២៤ សម្រាប់ប្រតិបត្តិការចំណូល-ចំណាយរបស់រាជរដ្ឋាភិបាលផងដែរ ហើយធនាគារអេស៊ីលីដា ក៏ត្រូវបានជ្រើសរើសធ្វើជាដៃគូក្នុងការអនុវត្តសាកល្បងនៅខេត្តចំនួន២គឺខេត្តបន្ទាយមានជ័យ និងខេត្តកណ្តាល សម្រាប់ប្រតិបត្តិការចំណូល-ចំណាយ នៅក្នុងឆមាសទី២ ឆ្នាំ២០០៩។

បន្ទាប់ពីត្រូវបានបង្កើតនៅក្នុងឆ្នាំ ២០០៧ អង្គភាពគ្រប់គ្រងសាច់ប្រាក់បានរៀបចំចងក្រងតារាងចំណាយ-ចំណូលតាមក្រសួង ស្ថាប័ន ផ្អែកតាមជំពូក តាមគណនី និង អនុគណនី ដោយបានបញ្ចូលទិន្នន័យឆ្នាំ ២០០៧ និងធ្វើបច្ចុប្បន្នភាពទិន្នន័យឆ្នាំ ២០០៨។ គំរូរបាយការណ៍ស្តីពីស្ថានភាពសាច់ប្រាក់របស់រដ្ឋ តារាងគំរូព្យាករណ៍ប្រចាំខែ តារាងប្រៀបធៀបរវាងផែនការ និងការអនុវត្តជាក់ស្តែង និងរបាយការណ៍ស្តីពីសមតុល្យសាច់ប្រាក់ប្រចាំខែ/សប្តាហ៍/ថ្ងៃ ត្រូវបានរៀបចំបង្កើតឡើង។ អង្គភាពគ្រប់គ្រងសាច់ប្រាក់តាមរយៈជំនួយបច្ចេកទេសពីអ្នកជំនាញការអន្តរជាតិក៏កំពុងកំណត់ទម្រង់និងរៀបចំម៉ូដែលសម្រាប់ការព្យាករណ៍លំហូរសាច់ប្រាក់ផងដែរ។

- **បន្តកែលម្អលទ្ធកម្មសាធារណៈ**

នៅក្នុងដំណើរការកែលម្អនីតិវិធីចំណាយ លទ្ធកម្មសាធារណៈត្រូវបានធ្វើវិសហមជ្ឈការទៅឱ្យក្រសួង ស្ថាប័ន។ គំរូតារាងផែនការ និងរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មត្រូវបានធ្វើការកែលម្អឱ្យប្រសើរឡើង ហើយក៏មានការរៀបចំវគ្គផ្សព្វផ្សាយអំពីការធ្វើផែនការលទ្ធកម្មប្រចាំឆ្នាំ២០០៩ ដល់ក្រសួង ស្ថាប័នផងដែរ។ ដោយឡែកនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការិយាល័យសវនកម្មលទ្ធកម្ម ដើម្បីបំពេញសវនកម្មកិច្ចលទ្ធកម្មជាក្រោយត្រូវបានបង្កើតឡើងដោយបានជ្រើសរើសមន្ត្រីថ្មីចំនួន ០៦ រូបបន្ថែម និងបានបញ្ជូនមន្ត្រីចំនួន ០៦រូបទៅចូលរួមវគ្គបណ្តុះបណ្តាលចំនួន០២លើកនៅម៉ាឡេស៊ី និងសិង្ហបុរី ហើយកំពុងដំណើរការជ្រើសរើសទីប្រឹក្សាអន្តរជាតិដើម្បីជួយរៀបចំច្បាប់លទ្ធកម្មសាធារណៈ ការរៀបចំយុទ្ធសាស្ត្រត្រួតពិនិត្យជាក្រោយ (Post Review) និងការវាយតម្លៃប្រព័ន្ធលទ្ធកម្មសាធារណៈ និងជ្រើសរើសអ្នកជំនាញការក្នុងស្រុកដើម្បីរៀបចំគេហទំព័រលទ្ធកម្ម(E-Procurement Website) ផងដែរ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការផ្តល់ព័ត៌មានពីលទ្ធកម្មសាធារណៈ។

IRRPP ត្រូវបាន ធ្វើការពិនិត្យ និងកែលម្អឡើងវិញ។ សេចក្តីព្រាងច្បាប់លទ្ធកម្មបឋម ត្រូវបានបកប្រែជា ភាសាខ្មែរ និងបានដាក់ឱ្យមានការពិភាក្សានៅក្នុងក្របខ័ណ្ឌនាយកដ្ឋានលទ្ធកម្ម។ នាយក-ដ្ឋានលទ្ធកម្ម ក៏បានពិភាក្សាលើការរៀបចំបង្កើតការិយាល័យផែនការលទ្ធកម្មសាធារណៈ។

### ៤.២ សកម្មភាពជំហានទី ២ ដែលត្រូវអនុវត្តនៅក្នុងដំណាក់កាលទី២

នៅក្នុងដំណើរការឆ្ពោះទៅរកការសម្រេចឱ្យបាននូវការធ្វើឱ្យប្រសើរឡើងគណនេយ្យភាពហិរញ្ញវត្ថុ ដែលជាគោលបំណងចំបងជាយុទ្ធសាស្ត្រនៃជំហានទី ២ នោះចង្កោមសកម្មភាពការងារត្រូវបានចងក្រងនៅជុំវិញវិញគោលបំណងចំនួន០៨ដែលជោគជ័យក្នុងគោលបំណងទាំងអស់នេះ នឹងនាំឱ្យគណនេយ្យភាពហិរញ្ញវត្ថុត្រូវបានកែលម្អប្រសើរឡើង។

- **កែលម្អបន្ទាត់គណនេយ្យភាពដោយកំណត់ឱ្យបានច្បាស់ពីតួនាទី មុខងារ និង ការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន គ្រប់កម្រិត និងរបស់អង្គភាពក្រោមឱវាទ**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំពុងសិក្សាជាបណ្តើរៗលើក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពថវិកា ព្រមទាំងអ្នកគ្រប់គ្រងថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដំណើរការវិភាគមុខងារសម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចាប់ផ្តើមដោយបានស្នើឡើងនូវវិធីសាស្ត្រនៃការអនុវត្តវិភាគមុខងារ និងយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស របាយការណ៍នេះ នឹងត្រូវដាក់ឱ្យមានការពិភាក្សាពីគ្រប់អគ្គនាយកដ្ឋាន/នាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅដើមខែមេសានេះ។ ការសិក្សាអភិក្រមការងារថ្មីក៏បាន ចាប់ដំណើរការជាបណ្តើរៗផងដែរក្រោមគម្រោង FMIS។ បន្ថែមលើនេះដែរ កសហវ បានពង្រាយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទៅប្រចាំនៅក្រសួងស្ថាប័នចំណាយបានចំនួន ១១ (ក្នុងឆ្នាំ ២០០៨ មានចំនួន០៩) និងកំពុងត្រៀមរៀបចំពង្រាយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទៅតាមបណ្តាក្រសួង ស្ថាប័នបន្ថែមទៀត។

- **កែលម្អឧបករណ៍ដែលជំរុញឱ្យមានការទទួលខុសត្រូវចំពោះការគ្រប់គ្រងហិរញ្ញវត្ថុ និងការពង្រឹងគណនេយ្យភាព ២២**

ក្របខ័ណ្ឌច្បាប់ និងឧបករណ៍លើកទឹកចិត្តត្រូវបានធ្វើការពិនិត្យ និងសិក្សាឡើងវិញដើម្បីជួយជម្រុញប្រសិទ្ធភាពក្នុងការងារ។ ថវិកាតាមកម្មវិធី និងផែនការយុទ្ធសាស្រ្តថវិកាត្រូវបានកែលម្អ និងពង្រឹងបន្ថែម ព្រមជាមួយការអនុវត្តប្រព័ន្ធរបាយការណ៍ពិនិត្យមើលសមិទ្ធ-កម្មនៃការប្រើប្រាស់ថវិកា ដែលនេះជាឧបករណ៍សម្រាប់ការវិភាជន៍ថវិកា។ ក្រសួងបន្តអនុវត្តការពង្រឹងវិន័យនៃការគ្រប់គ្រងថវិកា និងការពង្រឹងឱ្យអនុវត្តថវិកាស្របជាមួយបទ-ប្បញ្ញត្តិ និងវិធានច្បាប់ជាធរមាន ដូចជាច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៨។

- **បន្តកែលម្អការអនុវត្តមាតិកាថវិកាថ្មី និង ប្លង់គណនេយ្យថ្មី**

សេចក្តីព្រាងចំណាត់ថ្នាក់សេដ្ឋកិច្ច ជាអនុ-អនុគណនីផ្នែកចំណូល ត្រូវបានរៀបចំដោយនាយកដ្ឋានថវិកា និងសេចក្តីព្រាងនេះត្រូវបានដាក់ឱ្យមានការពិភាក្សាជាមួយនាយកដ្ឋានពាក់ព័ន្ធ។ មាតិកាថវិកា និងមាតិកាគណនេយ្យថ្មីក៏ត្រូវបានធ្វើបច្ចុប្បន្នភាពទៅក្នុងTOFE និងភ្ជាប់ពី TOFE ទៅ GFS ។ GFS ត្រូវបានដាក់ចេញសាកល្បងចាប់ពីខែឧសភា ឆ្នាំ ២០០៨។ ដោយឡែករតនាគារជាតិបានចងក្រងសៀវភៅឯកសារមួយចំនួន ដូចជាប្លង់គណ-នេយ្យថ្មី សារាចរណែនាំ សៀវភៅណែនាំតម្រង់ទិសការអនុវត្តមាតិកាថវិកា និងប្លង់គណនេយ្យថ្មី និងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធការងាររតនាគារ ទាំងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន។ វគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធជាមួយប្រតិបត្តិការនៃប្លង់គណនេយ្យថ្មី ត្រូវបានរៀបចំដល់មន្ត្រីអគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានថវិកា នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន រតនាគារខេត្ត ក្រុង និងបណ្តាក្រសួង ស្ថាប័ន។ វគ្គបណ្តុះបណ្តាលស្តីពីវិធានថ្មីដែលពាក់ព័ន្ធជាមួយប្រតិបត្តិការនៃប្លង់គណនេយ្យថ្មីត្រូវបានរៀបចំចំនួន០២ លើកសម្រាប់មន្ត្រីនៃអគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានថវិកា នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន រតនាគារខេត្ត និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។ ប្លង់គណនេយ្យថ្មីសម្រាប់ថវិកាឃុំ-សង្កាត់ ក៏កំពុងត្រូវបានពិនិត្យឡើងវិញដើម្បីធ្វើការកែលម្អ។ ក្រុមជំនួយបច្ចេកទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បន្ទាប់ពីបំពេញការងារជាមួយនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធបានរៀបចំរបាយការណ៍អំពីចំណាត់ថ្នាក់ថវិកា និងរបាយការណ៍គណនេយ្យដែលរបាយការណ៍ទាំងនេះ នឹងត្រូវដាក់ឱ្យមានការពិភាក្សានៅក្នុងក្រុមរៀបចំថវិកា និងក្រុម

អនុវត្តថវិកា។ ការវាយតម្លៃទ្រព្យសម្បត្តិនៅគ្រប់ក្រសួង មន្ទីរ ត្រូវបានស្នើឡើងនៅក្នុងដំណើរការជាជំហានៗឆ្ពោះទៅអនុវត្តគណនេយ្យបង្គរ។

- **កែលម្អដំណើរការ និងប្រតិបត្តិការអនុវត្តថវិកា**

នីតិវិធីបុរេប្រទានត្រូវបានពិនិត្យ និងសិក្សាឡើងវិញ ហើយអនុក្រឹត្យស្តីពីនីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយចរន្ត និងចំណាយវិនិយោគសាធារណៈក៏កំពុងត្រូវបានរៀបចំផងដែរ។ ការជ្រើសរើសទីប្រឹក្សាផ្នែកអនុវត្តថវិកាកំពុងដំណើរការ។

នៅក្នុងដំណើរការនៃការដាក់ឱ្យអនុវត្តគម្រោងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា ការបង្កើនកម្រិតយល់ដឹង និងកសាងសមត្ថភាពរបស់មន្ត្រីពាក់ព័ន្ធត្រូវបានអនុវត្តជាហូរហែរក្នុងនោះមន្ត្រីជំនាញផ្នែកព័ត៌មានវិទ្យាចំនួន ១៤រូប ត្រូវបានទទួលការបណ្តុះបណ្តាលផ្នែកព័ត៌មានវិទ្យាជាមូលដ្ឋានចំនួន០៦វគ្គសិក្សា។ ក្រុមការងារអនុវត្តគម្រោង GFMIS ត្រូវបានបង្កើតនៅគ្រប់នាយកដ្ឋានរបស់កសហវ និងនៅតាមក្រសួងអាទិភាពចំនួន០៥ (ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងក្រសួងអភិវឌ្ឍន៍ជនបទ)។ មន្ត្រីសមាជិកក្រុមការងារអនុវត្តគម្រោង GFMIS ចំនួន១១០រូបបានទទួលការបណ្តុះបណ្តាលផ្នែកនីតិវិធីអនុវត្តការងារ(មាតិកាគណនេយ្យ មុខងាររបស់ GFMIS និង គណនេយ្យរបស់រដ្ឋ) និងវគ្គបណ្តុះបណ្តាលផ្នែកគ្រប់គ្រងការផ្លាស់ប្តូរ ហើយសិក្ខាសាលាស្តីពីបទពិសោធន៍នៃការអនុវត្តគម្រោង FMIS និងការបង្ហាញផលិតផលកម្មវិធីកុំព្យូទ័រ ក៏ត្រូវបានរៀបចំបង្ហាញដល់មន្ត្រីទាំងអស់នេះផងដែរ។ ដំណាក់កាលទី២ នៃការដេញថ្លៃគម្រោងកំពុងដំណើរការ ឯកសារដេញថ្លៃដំណាក់កាលទី ២ ត្រូវបានរៀបចំហើយរង់ចាំការផ្តល់ការយល់ព្រមពីធនាគារពិភពលោក។ ឯកសារនីតិវិធីអនុវត្តការងារ និងឯកសារគ្រប់គ្រងការផ្លាស់ប្តូរ ត្រូវបានរៀបចំឡើងដោយមានជំនួយពីទីប្រឹក្សាផ្នែកវិភាគមុខងារ និងនីតិវិធីអនុវត្តការងារនិង ទីប្រឹក្សាផ្នែកគ្រប់គ្រងការផ្លាស់ប្តូរ។

- **កែលម្អប្រព័ន្ធគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុដើម្បីធានាតម្លាភាព**

ការអនុវត្តប្រព័ន្ធ **software Conical Hat** ត្រូវបានពង្រឹងបន្ត ដើម្បីកែលម្អប្រសិទ្ធភាពរបាយការណ៍គណនេយ្យ និងអាចប្រើប្រាស់តាមគ្រប់នាយកដ្ឋាន។ ការជ្រើសរើសទីប្រឹក្សា

អន្តរជាតិផ្នែកគណនេយ្យដើម្បីផ្តល់ជំនួយបច្ចេកទេសដល់អគ្គនាយកដ្ឋានរតនាគារជាតិកំពុងដំណើរការ។ប្លង់មាតិកាគណនេយ្យថ្មី ត្រូវបានពិនិត្យមើលឡើងវិញ និងការបណ្តុះបណ្តាលបន្ត និង វាយតម្លៃលើកម្រិតបទដ្ឋាននៃមាតិកាគណនេយ្យនេះ ត្រូវបានចាប់អនុវត្ត ដោយប្រៀបធៀបទៅនឹងបទដ្ឋានអន្តរជាតិ និងគំរូដែលត្រូវប្រើប្រាស់ក្នុងគម្រោង FMIS។ របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាត្រូវបានបន្តកែលម្អ និងពង្រឹងបន្ថែមទៀតដោយក្រសួង ស្ថាប័នជាពិសេសក្រសួងដែលអនុវត្តថវិកាតាមកម្មវិធី។ទម្រង់របាយការណ៍អំពីសមិទ្ធកម្មនៃការអនុវត្តថវិកាប្រចាំឆ្នាំ ត្រូវបានព្រាង និងធ្វើការពិភាក្សាក្នុងកម្រិតបច្ចេកទេស។ វគ្គបណ្តុះបណ្តាលសម្រាប់រតនាគារថ្នាក់កណ្តាល និងថ្នាក់ខេត្ត ត្រូវបានរៀបចំឡើងដើម្បីផ្សព្វផ្សាយអំពីប្រព័ន្ធកត់ត្រា និងរបាយការណ៍តាមប្លង់គណនេយ្យថ្មី និងការប្រើប្រាស់ **software Conical Hat** ។

អត្ថបទថវិកាសង្ខេបត្រូវបានបោះផ្សាយជារៀងរាល់ឆ្នាំសម្រាប់សាធារណៈជនចាប់ពីឆ្នាំ២០០៧មក ហើយដែលអត្ថបទនេះនឹងត្រូវមានការកែលម្អបន្ថែមទៀតផងដែរ។

- **កែលម្អសវនកម្ម និងអធិការកិច្ច ព្រមទាំងឆ្លើយតបទៅ និងប្រើប្រាស់លទ្ធផលនៃរបាយការណ៍សវនកម្ម និងអធិការកិច្ច**

នៅចុងឆ្នាំ ២០០៧ ក្រសួងចំនួន ២៣ ដែលបានបង្កើតសវនកម្មផ្ទៃក្នុងរបស់ខ្លួននិងមានតែចំនួន ១១ ដែលមានដំណើរការពេញលេញ បច្ចុប្បន្នក្រសួងចំនួន២៥ មាននាយកដ្ឋានសវនកម្មផ្ទៃក្នុង និងមានដំណើរការពេញលេញចំនួន១១ ទន្ទឹមនឹងនេះសហគ្រាសសាធារណៈ ចំនួន ០៣ បានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង និងមានដំណើរការ។ ផែនការសវនកម្មប្រចាំឆ្នាំ ២០០៨ និងសម្រាប់រយៈពេល ០៣ ឆ្នាំ (២០០៨-២០១០) ត្រូវបានរៀបចំឡើង ព្រមជាមួយនេះដែរ សេចក្តីព្រាងនីតិវិធីសវនកម្មផ្ទៃក្នុងសម្រាប់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានចាប់ផ្តើមរៀបចំជាបណ្តើរៗ ហើយគំរូរបាយការណ៍សវនកម្មត្រូវបានធ្វើការកែលម្អឡើងវិញមួយចំនួន។ ការជ្រើសរើសទីប្រឹក្សាជាតិ និងអន្តរជាតិផ្នែកសវនកម្មបានជិតបញ្ចប់សព្វគ្រប់ដើម្បីផ្តល់ជំនួយបច្ចេកទេសផ្នែកយុទ្ធសាស្រ្ត និងការអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋាន។ផែនការបណ្តុះបណ្តាលជំហានទី២សម្រាប់មន្ត្រីសវនកម្មផ្ទៃក្នុង ដែលជាផែនការបណ្តុះបណ្តាលរយៈពេល ០៣ ឆ្នាំ ត្រូវបានរៀបចំ

ចប់សព្វគ្រប់ និងត្រូវបានដាក់បញ្ចូលក្នុងផែនការបណ្ដុះបណ្ដាលរួមរយៈពេល ០៣ ឆ្នាំ។ ប្រអប់សំបុត្រសវនកម្មចំនួន៣០ ត្រូវបានធ្វើរួចរាល់ និងត្រៀមដំឡើងនៅរាជធានី-ខេត្ត ចំនួន ២៣។

**- ពង្រឹង និងរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រវិមជ្ឈការហិរញ្ញវត្ថុ**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពថវិកាព្រមទាំងអ្នកគ្រប់គ្រងថវិកាសម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិកំពុងត្រូវបានធ្វើការសិក្សាជាបណ្ដើរៗ។ សារាចរណែនាំស្ដីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា និងសារាចរណែនាំស្ដីពីការអនុវត្តថវិកាត្រូវបានរៀបចំក្នុងន័យកែលម្អនីតិវិធីរៀបចំ និងអនុវត្តថវិកាសាលារាជធានី ខេត្ត ដើម្បីឱ្យស្របគ្នាទៅនឹងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ។ សេចក្ដីព្រាងអំពីការបែងចែកចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានរៀបចំ និងដាក់ឱ្យមានការផ្ដល់យោបល់ពីនាយកដ្ឋានពាក់ព័ន្ធ ព្រមជាមួយការសិក្សាជម្រើសអំពីនីតិវិធីថវិកាស្វយ័ត និងថវិកាឯកភាពនៅតាមរាជធានីខេត្ត។ ឯកសារ និងអនុសាសន៍ស្ដីពីការកែលម្អការអនុវត្តថវិកាឃុំ-សង្កាត់ ត្រូវបានចងក្រងឡើងនិងសិក្ខាសាលាពីការអនុវត្តថវិកាឃុំ-សង្កាត់ ត្រូវបានរៀបចំផ្សព្វផ្សាយនៅខេត្តចំនួន០២ (កំពង់ស្ពឺ និងកំពង់ចាម)។ ក្រុមការងារដើម្បីធ្វើវិសោធនកម្មច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិខេត្ត ក្រុង ត្រូវបានបង្កើត និងបានរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយក៏កំពុងសិក្សាលើការរៀបចំយុទ្ធសាស្ត្ររយៈពេលខ្លី និងវែងសម្រាប់អនុវត្តវិមជ្ឈការសារពើពន្ធ និងចូលរួមរៀបចំតាក់តែងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យរយៈពេល១០ឆ្នាំ ដោយសហការជាមួយគណៈកម្មាធិការជាតិអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ស្របពេលជាមួយគ្នានេះដែរ នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ក៏មានការពិភាក្សាជាមួយធនាគារអភិវឌ្ឍន៍អាស៊ីក្នុងការស្វែងរកជំនួយបច្ចេកទេសបន្ថែមដើម្បីជួយពង្រឹងសមត្ថ-ភាពរបស់នាយកដ្ឋាន។

**- ការកសាងសមត្ថភាពស្ថាប័ន និងវិធានការលើកទឹកចិត្ត**

និស្សិតចំនួន ០៦ រូបត្រូវបានជ្រើសរើសឱ្យទៅបន្តការសិក្សាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់នៅប្រទេសអូស្ត្រាលីដើម្បីសិក្សាផ្នែកពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។វគ្គបណ្តុះបណ្តាលជំនាញឯកទេសដូចជាផ្នែកគណនេយ្យ សវនកម្ម ព័ត៌មានវិទ្យា លទ្ធកម្មសាធារណៈ ការគ្រប់គ្រងថវិកា ភាសាអង់គ្លេស ចំនួន ៥១លើក ត្រូវបានរៀបចំឡើងសម្រាប់មន្ត្រីរាជការ កសហវ និងក្រសួង ស្ថាប័នពាក់ព័ន្ធ សរុបចំនួន១៥៥២នាក់។ ទន្ទឹមនឹងនេះសិក្ខាសាលាបច្ចេកទេសចំនួន៣៧លើកក៏ត្រូវបានរៀបចំដោយមានសិក្ខាកាមចូលរួមចំនួន៣១៣៤នាក់។ការជ្រើសរើសមន្ត្រីរាជការបន្ថែមដើម្បីបំពេញតម្រូវការតាមជំនាញក៏ត្រូវបានអនុវត្តផងដែរ ដោយបានជ្រើសរើសមន្ត្រីរាជការចំនួន ៧៣នាក់ បម្រើការងារនៅអគ្គនាយកដ្ឋានរតនាគារជាតិ។ ទីប្រឹក្សាអន្តរជាតិផ្នែកបណ្តុះបណ្តាលត្រូវបានជ្រើសរើសដើម្បីឱ្យជួយសិក្សាពិនិត្យឡើងវិញ និងរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្របណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងវែង និងជួយរៀបចំការដាក់អនុវត្តផែនការកសាងសមត្ថភាពដំណាក់កាលទី ២។ របាយការណ៍ស្តីពីវិធីសាស្ត្រ វិភាគមុខងារសម្រាប់ កសហវ ត្រូវបានរៀបចំក្រោមជំនួយបច្ចេកទេសពីទីប្រឹក្សាអន្តរជាតិ ដែលរបាយការណ៍នេះនឹងត្រូវដាក់ឱ្យមានការពិនិត្យ និងពិភាក្សាក្នុងក្របខ័ណ្ឌ កសហវ នៅដើមខែមេសា។ ការជ្រើសរើសទីប្រឹក្សាអន្តរជាតិផ្នែកគ្រប់គ្រងធានធានកំពុងស្ថិតក្នុងដំណាក់កាលចរចាចុងក្រោយ ដែលរំពឹងថានឹងអាចចាប់ផ្តើមការងារនៅដើមខែឧសភានេះ។

ការលើកទឹកចិត្តមន្ត្រីរាជការតាមរយៈការផ្តល់ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ នឹងត្រូវពង្រីកបន្ថែមសម្រាប់មន្ត្រីរាជការកសហវ ពីចំនួន ២៤៧នាក់ ទៅ ៥១០នាក់ និងត្រូវផ្តល់មន្ត្រីនៃក្រសួង ស្ថាប័នដែលរួមចំណែកក្នុងកម្មវិធីកំណែទម្រង់ចំនួន ២៥០ នាក់ផងដែរ។ ឯកសារសម្រាប់ការអនុវត្តប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារត្រូវបានរៀបចំ និងដាក់ឱ្យមានការពិនិត្យពិភាក្សាជាមួយតំណាងដៃគូអភិវឌ្ឍន៍ហើយរំពឹងថាប្រាក់លាភការនេះ នឹងអាចចាប់ផ្តើមអនុវត្តបានក្នុងខែមិថុនា។

### ៤.៣ សកម្មភាពសម្រាប់ជំហានបន្ទាប់ដែលត្រូវចាប់ផ្តើមជាបណ្តើរៗ

វឌ្ឍនភាពនៃសកម្មភាពជំហានបន្ទាប់ គឺមានគោលបំណងកែលម្អ និងពង្រឹកការអនុវត្តថវិកាតាមកម្មវិធី ព្រមទាំងកែលម្អភាពគ្រប់ជ្រុងជ្រោយ និងសមាហរណកម្មនៃថវិកា។

**_ការកែលម្អ និងការពង្រឹកការអនុវត្តថវិកាតាមកម្មវិធី**

សេចក្តីណែនាំអំពីថវិកាតាមកម្មវិធីត្រូវបានរៀបចំរួចរាល់ និងដាក់សុំការអនុម័តដើម្បីបោះពុម្ពផ្សាយ ។ វគ្គបណ្តុះបណ្តាលអំពីថវិកាតាមកម្មវិធីត្រូវបានរៀបចំសម្រាប់មន្ត្រីទទួលបន្ទុករៀបចំថវិកា អ្នកគ្រប់គ្រងថ្នាក់កណ្តាល និងអ្នកសម្រេចចិត្តផ្នែកនយោបាយ។ ទន្ទឹមនឹងនេះ កសហវ នៅបានបន្តបំពេញការងារជាមួយក្រសួងដែលអនុវត្តថវិកាតាមកម្មវិធីដើម្បីកែលម្អរចនាសម្ព័ន្ធកម្មវិធី ការគិតគូរចំណាយ ការរៀបចំសូចនាករ ការកំណត់គោលដៅ និងការធ្វើរបាយការណ៍អំពីសមិទ្ធកម្ម។ ការជ្រើសរើសទីប្រឹក្សាអន្តរជាតិផ្នែកថវិកា និងអ្នកជំនាញតាមវិស័យពាក់ព័ន្ធនឹងថវិកាតាមកម្មវិធីកំពុងដំណើរការ។

**_បន្តកែលម្អភាពគ្រប់ជ្រុងជ្រោយ និង ការធ្វើសមាហរណកម្មថវិកា**

សេចក្តីព្រាងបឋមនៃសេចក្តីណែនាំអំពីផែនការយុទ្ធសាស្រ្តថវិកាត្រូវបានរៀបចំហើយ នឹងដាក់ឱ្យមានការពិភាក្សាផ្ទៃក្នុងនាយកដ្ឋាននៅសប្តាហ៍បន្ទាប់។ សិក្ខាសាលាបច្ចេកទេសជាខ្សែសង្វាក់នឹងត្រូវរៀបចំដើម្បីកែលម្អជាបន្តការរៀបចំផែនការយុទ្ធសាស្រ្តថវិកា។ បន្ថែមលើនេះ លក្ខណៈវិនិច្ឆ័យការវាយតម្លៃ និងការដាក់ពិន្ទុផែនការយុទ្ធសាស្រ្តថវិកាត្រូវបានពិនិត្យឡើងវិញ និងធ្វើការកែលម្អឱ្យប្រសើរឡើង។ ក្របខ័ណ្ឌច្បាប់គ្រប់គ្រងថវិកាក្រៅបរិបទ ជាពិសេសសម្រាប់សហគ្រាសសាធារណៈ និងអង្គភាពថវិកាស្វយ័តកំពុងត្រូវបានពិនិត្យមើលឡើងវិញ ហើយសេចក្តីព្រាងគំរូរបាយការណ៍ចំណូល-ចំណាយ ដែលអនុវត្តក្រៅបរិបទថវិកា ក៏ត្រូវបានរៀបចំផងដែរ។ ការកែលម្អកម្មវិធីវិនិយោគសាធារណៈកំពុងត្រូវបានដាក់ឱ្យមានការពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ហើយការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ( MTEF ) ២០០៩-២០១១ ក៏ត្រូវបានដំណើរជិតរួចរាល់ដែរ (ព្រមទាំងបានបកជាភាសាខ្មែរ) ដើម្បីឆ្លើយតបនឹងគោលនយោបាយសម្រាប់ធ្វើសមា-ហរណកម្មថវិកា និងបន្តកែលំអការធ្វើសមាហរណកម្មថវិកាចរន្ត និងមូលធន។

**៥_ បញ្ហាប្រឈម**

នៅក្នុងដំណើរការអនុវត្តផែនការសកម្មភាពកំណែទម្រង់ បញ្ហាប្រឈមមួយចំនួនកើតមានដែលតម្រូវឱ្យមានការគិតគូរ និងស្វែងរកដំណោះស្រាយ ដែលបញ្ហាប្រឈមសំខាន់ៗទាំងនោះមានដូចជា:

-ការតម្រូវឱ្យមានការជ្រើសរើសទីប្រឹក្សាបច្ចេកទេស និងសម្ភារៈគាំទ្រឱ្យបានទាន់ពេលវេលា
-ការផ្តល់ការលើកទឹកចិត្តបន្ថែមទៀតដល់មន្ត្រីអនុវត្តការងារ
-តម្រូវការនៃការបណ្តុះបណ្តាលបន្ថែម និងការជ្រើសរើសមន្ត្រីមានសមត្ថភាពបន្ថែម
-កិច្ចសហការ និងសម្របសម្រួលរវាងក្រសួង ស្ថាប័ន និងនៅក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ននីមួយៗផ្ទាល់ ត្រូវតែមានភាពសកម្មថែមទៀត
-តម្រូវការនៃភាពជាម្ចាស់ និងភាពសកម្មក្នុងការងារបន្ថែមទៀត របស់អគ្គនាយកដ្ឋាន/នាយកដ្ឋាន/អង្គភាពនៃក្រសួង ស្ថាប័ននីមួយៗដែលទទួលបន្ទុកអនុវត្តការងារកំណែទម្រង់។

## ៦. សេចក្តីសន្និដ្ឋាន

ជារួម ភាពជឿទុកចិត្តបាននៃថវិកា នៅតែអាចរក្សាបានមាំទាំ ទោះបីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវការនូវពេលវេលាអន្តរកាលដើម្បីផ្លាស់ប្តូរពីដំណាក់កាលទី ១ ទៅដំណាក់កាលទី ២ក៏ដោយ។

ផែនការសកម្មភាពដំណាក់កាលទី២ បានកំណត់យ៉ាងច្បាស់លាស់នូវគោលដៅគោលបំណង និងចង្កោមសកម្មភាពដែលអនុវត្តដើម្បីសម្រេចគោលបំណងនីមួយៗ ព្រមជាមួយនេះដែរ ផែនការសកម្មភាពនាយកដ្ឋានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងផែនការសកម្មភាពក្រសួង ស្ថាប័ន បានរៀបចំជាលំអិតនូវបណ្តាសកម្មភាពជាក់ស្តែង មានលក្ខណៈពេញលេញ និងគ្រប់គ្រាន់ ដែលអាចធានាថាភាពជោគជ័យនៃផែនការសកម្មភាពកំណែទម្រង់ដំណាក់កាលទី ២ នឹងកើតមានពិតប្រាកដ។ ព្រមជាមួយនេះដែរ ក្របខ័ណ្ឌនិងយន្តការស្ថាប័នគ្រប់គ្រង សម្របសម្រួល និងត្រួតពិនិត្យ ត្រូវបានរៀបចំច្បាស់លាស់ និងមានលក្ខណៈពេញលេញ ដែលអនុញ្ញាតឱ្យអាចត្រួតពិនិត្យបានជាប្រចាំវឌ្ឍនភាពនៃដំណាក់កាលទី ២។

វឌ្ឍនភាពក្នុងការអនុវត្តសកម្មភាពការងារដំណាក់កាលទី ២ ត្រូវបានមើលឃើញថាសម្រេចបានសមល្មម ទោះបីជាផ្នែកខ្លះនៅមានកម្រិតនៅឡើយ ហើយដែលនៅក្នុងពេលនេះ លទ្ធផលជាផ្លែផ្កាជាក់ស្តែងមិនទាន់ចេញជារូបរាងច្បាស់នោះទេ ប៉ុន្តែសមិទ្ធផលក្នុងកម្រិតនេះ គឺជារឿងធម្មតានៅក្នុងដំណាក់កាលរៀបចំដែលមានលក្ខណៈជាយុទ្ធសាស្ត្រ ហើយប្រសិនបើពិនិត្យមើលគោលបំណងទាំង០៨សម្រាប់ការសម្រេចគោលបំណងជាយុទ្ធ-សាស្ត្រនៃជំហានទី២ និងគោលបំណង០២សម្រាប់ជំហានក្រោយៗ ដែលបានរាយការណ៍

ខាងលើនេះ ដោយធ្វើការប្រៀបធៀបជាមួយសូចនាករណ៍គន្លឹះទាំង១០ ដែលប្រើភ្លើងពណ៌ជាសញ្ញានោះ ជាការពិតណាស់ថាសូចនាករណ៍មួយចំនួនបានឆ្លងផុតពីពណ៌ក្រហមហើយ។

----------------------